## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

## "នីហុងហ្គូ ខារ៉ាវ៉ាន"
## កម្មវិធីកម្មសិក្សា ផ្សព្វផ្សាយវប្បធម៌ និងភាសាជប៉ុននៅកម្ពុជា

ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៦

សាស្ត្រាចារ្យ គ្រូបង្រៀន និង និស្សិតភាសាជប៉ុន នឹងធ្វើការបង្ហាញពីវប្បធម៌ និងភាសាជប៉ុនដល់សិស្សានុសិស្សនៅវិទ្យាល័យ១៥នៅទីក្រុង និងតាមបណ្តាខេត្តនៃប្រទេសកម្ពុជា ចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៦។

ពួកគេនឹងរៀបចំសកម្មភាពនានាដូចជា សំនួរល្បងប្រាជ្ញាអំពីប្រទេសជប៉ុន សាកល្បងរៀនភាសាជប៉ុន ស្លៀកសំលៀកបំពាក់ប្រពៃណីជប៉ុន បត់ក្រដាស់អូរីហ្គាមិ និង ចែករំលែកបទពិសោធការសិក្សានៅប្រទេសជប៉ុនជាមួយសិស្សានុសិស្ស។

កម្មវិធីនេះសហការរៀបចំដោយដេប៉ាតឺម៉ងភាសាជប៉ុននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំច្បាប់ជប៉ុនណាហ្គូយ៉ា និង កម្មវិធីសិក្សាភាសាជប៉ុនអង្គការJICA នៃសាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យមេគង្គកម្ពុជា មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន។

កម្មវិធីនេះមានគោលបំណង ផ្តល់ឱកាសដល់យុវសិស្សកម្ពុជាឲ្យទទួលបាននូវបទពិសោធវប្បធម៌ និង ភាសាជប៉ុននៅស្រុកកំណើតពួកគេតែម្តង។ យុវជនកម្ពុជាដែលមិនអាចចូលរួមកម្មវិធីវប្បធម៌ជប៉ុនបានដោយងាយស្រួលនៅរាជធានី ក៏អាចយល់ដឹងពីប្រទេសជប៉ុនកាន់តែស៊ីជម្រៅ ដែលនឹងនាំឲ្យការពង្រឹងចំណងមិត្តភាពរវាងកម្ពុជា និងជប៉ុនកាន់តែរឹងមាំថែមទៀត។

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161*
*Email: info.jpn@pp.mofa.go.jp*
*Official Website: www.kh.emb-japan.go.jp*